004/07-09-2009-អ.វ.ត.ក-ក.ស.ច.ស លេខ / N°: 9281

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
សំណុំរឿងព្រហ្មទណ្ឌ
**Criminal Case File /Dossier pénal**
**លេខ/No:004/07-09-2009-ECCC-OCIJ**

# កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង
# Written Record of Initial Appearance
# Procès-Verbal d'Interrogatoire de Première Comparution

នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១២ និង ៥៧ នាទី រសៀល ការបង្ហាញខ្លួនលើកដំបូងរបស់ លោក យឹម ទិត្យ បានធ្វើឡើងនៅក្នុងបរិវេណនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា("អ.វ.ត.ក") នៅភ្នំពេញ ដោយមានវត្តមានដូចខាងក្រោម៖

ចៅក្រម Michael Bohlander សហចៅក្រមស៊ើបអង្កេតអន្តរជាតិ("ស.ច.ស.អ")
អ្នកស្រី ឆាយ ច័ន្ទលីដា ជាក្រឡាបញ្ជី

ជនសង្ស័យ៖
លោក យឹម ទិត្យ

សម្រាប់ក្រុមមេធាវីការពារក្តីរបស់ យឹម ទិត្យ មាន៖
លោក សូ មូស្សេទ្ធី សហមេធាវីជាតិ
អ្នកស្រី Suzana Tomanović សហមេធាវីអន្តរជាតិ
អ្នកស្រី Kirsty Sutherland អ្នកប្រឹក្សាច្បាប់ជាន់ខ្ពស់
អ្នកស្រី សេង ចន្ទថូ អ្នកគ្រប់គ្រងសំណុំរឿង

សម្រាប់ការិយាល័យសហចៅក្រមស៊ើបអង្កេត មាន៖
អ្នកស្រី Kerryn Beaton មន្ត្រីច្បាប់
អ្នកស្រី Anna Katulu មន្ត្រីច្បាប់


ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 09 / 12 / 2015
ម៉ោង (Time/Heure): 15:50
[illegible]/Case File Officer/L'agent chargé du dossier: Sann Rada

01178394

០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស **លេខ៖** ១២៨១

លោក សួរ សុខាល័យ អ្នកបកប្រែភាសាដែលបានស្បថ នៅ អ.វ.ត.ក

លោក ងួន គីមលី អ្នកបកប្រែភាសាដែលបានស្បថ នៅ អ.វ.ត.ក

លោក ឃ្លោក ស្លួសសូឡាលីន មន្ត្រីបច្ចេកទេស នៅ អ.វ.ត.ក

អ្នកស្រី Vidya Kumar មន្ត្រីព័ត៌មានវិទ្យា នៅ អ.វ.ត.ក

អ្នកដែលមានវត្តមានទាំងអស់ ត្រូវបានជូនដំណឹងថា ការបង្ហាញខ្លួនលើកដំបូងនេះនឹងត្រូវថតយកសំឡេង/រូបភាព។

យឹម ទិត្យ បានជូនដំណឹងអំពីព័ត៌មានផ្ទាល់ខ្លួនរបស់គាត់ដូចខាងក្រោម៖

ឈ្មោះ៖ យឹម ទិត្យ

ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៣៦

ស្រុកកំណើត៖ ភូមិត្រពាំងគល់ ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ

សញ្ជាតិ៖ ខ្មែរ

មុខរបរ៖មន្ត្រីចូលនិវត្តន៍

ឈ្មោះឪពុក៖ យឹម ញ៉ែម (ស្លាប់)

ឈ្មោះម្តាយ៖ នាង សេង (ស្លាប់)

ឈ្មោះគ្រួសារ៖ អ៊ុង គេន (រស់)

ចំនួនកូន៖ បួននាក់

យឹម ទិត្យ បានប្រកាសថា គាត់ចេះអាន សរសេរ និងយល់ភាសាខ្មែរ ប៉ុន្តែ គាត់មិនចេះអាន សរសេរ ឬយល់ភាសាអង់គ្លេស ឬភាសាបារាំងទេ។ អាស្រ័យហេតុនេះ ច្បាប់ដើមនៃកំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងនេះ ត្រូវបានធ្វើប្រតិចារិកជាភាសាខ្មែរ ដោយអ្នកស្រី ឆាយ ច័ន្ទលីដា ជាក្រឡាបញ្ជី។

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា៖

- គាត់មានសិទ្ធិនៅស្ងៀមមិនឆ្លើយនឹងសំណួរ ហើយគ្មានសេចក្តីសន្និដ្ឋានអវិជ្ជមានណាមួយ អាចធ្វើឡើងដោយសារគាត់ប្រើប្រាស់សិទ្ធិនេះទេ។

- គាត់មានសេរីភាពក្នុងការធ្វើសេចក្ដីសន្និដ្ឋានមុនពេល ឬបន្ទាប់ពីការជូនដំណឹងអំពីបទចោទប្រកាន់។
- គាត់មានសិទ្ធិទទួលបានតំណាងផ្លូវច្បាប់ ហើយ
- គាត់អាចពិគ្រោះជាមួយសហមេធាវីរបស់គាត់មុនពេលគាត់ធ្វើសេចក្ដីសន្និដ្ឋានបែបនោះ។

ទាំងជនសង្ស័យ ទាំងសហមេធាវីរបស់គាត់ បានសម្រេចមិនធ្វើសេចក្ដីសន្និដ្ឋាន ឬក៏ដាក់សេចក្ដីសង្កេតនៅពេលនេះទេ។

ស.ច.ស.អ បានជូនដំណឹង ជនសង្ស័យ អំពីការចោទប្រកាន់អំពីអំពើឧក្រិដ្ឋដែល ស.ច.ស.អ បានទទួលពិនិត្យពីការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨("3IS") ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ("1SS") ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤("2SS") ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាក់ទងនឹងវត្តតាមះ ចុះនៅថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១៥("3SS") និងចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ ១ និងតំបន់ ៤ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥("4SS") (តទៅនេះ ហៅរួមថា "ដីកាសន្និដ្ឋាន និងចម្លើយតប") ហើយគាត់ត្រូវបានចោទថាជាអ្នកទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋដែលបានចោទទាំងនេះក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ម្នាក់របស់កម្ពុជាប្រជាធិបតេយ្យ ឬក៏ជាជនទទួលខុសត្រូវខ្ពស់បំផុតម្នាក់ចំពោះឧក្រិដ្ឋកម្មដែលបានចោទទាំងនេះ។

ស.ច.ស.អ បានប្រគល់ជូន យឹម ទិត្យ និងសហមេធាវីរបស់ គាត់ នូវសំណៅជាភាសាខ្មែរ និងអង់គ្លេសនៃដីកាសន្និដ្ឋាន និងចម្លើយតប ដូចបានបង្ហាញខាងលើ។

ស.ច.ស.អ បានកត់សម្គាល់ថា ការចូលពិនិត្យមើលសំណុំរឿងជាមុនត្រូវបានអនុញ្ញាតតាមរយៈដីកាសម្រេចចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៥។

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា អំពើឧក្រិដ្ឋដែលបានចោទដូចបានកំណត់នៅក្នុងដីកាសន្និដ្ឋាន និងចម្លើយតប ត្រូវបាន ក.ស.ព កំណត់លក្ខណៈបទល្មើស ដូចខាងក្រោម៖

- **ការរំលោភលើមាត្រា ២០៩, ២១០, ៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និង ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦** (មនុស្សឃាត ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើសាសនា)
- **ការរំលោភលើអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍**(អំពើប្រល័យពូជសាសន៍លើខ្មែរក្រោម និងវៀតណាម)
- **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**(ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា និងអំពើអមនុស្សធម៌ដទៃទៀត) និង
- **អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩**(ការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ការដកហូតសិទ្ធិ ឬការផ្លាស់ទីលំនៅ ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់)។

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា៖

- បទល្មើសទាំងនេះមានចែង និងផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៤, ៥,៦, ២៩ និង៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។
- អំពើឧក្រិដ្ឋដែលបានចោទទាំងនេះគឺស្ថិតនៅក្រោមការស៊ើបអង្កេតរបស់តុលាការ។
- ស.ច.ស.អ មិនជាប់កាតព្វកិច្ចត្រូវធ្វើតាមការកំណត់បទល្មើសដូចដែល ក.ស.ព បានសម្រេចទេ។

យឹម ទិត្យ ត្រូវបានជូនដំណឹងថា នៅពេលនេះ មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា គាត់អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋចាប់តាំងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ នៅទីតាំងដូចខាងក្រោមដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋាន និងចម្លើយតប។

**តំបន់ ១៣ ភូមិភាគនិរតី**

១. មន្ទីរសន្តិសុខវត្តប្រធាតុ (3IS កថាខណ្ឌ ៨០-៨១ និង 1SS កថាខណ្ឌ ១២-១៣)

២. មន្ទីរសន្តិសុខក្រាំងតាចាន់ (1SS កថាខណ្ឌ ១៤)

៣. ទីតាំងសម្លាប់មនុស្សភូមិព្រៃល (1SS កថាខណ្ឌ ១២ &១៤)

៤. ទីតាំងសម្លាប់មនុស្សវត្តអង្គុណា(1SS កថាខណ្ឌ ១២)

៥. ទីតាំងសម្លាប់មនុស្សព្រៃភូមិស្លែង (1SS កថាខណ្ឌ ១២ & ១៤)

៦. ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមុនី (1SS កថាខណ្ឌ ១៥)

**តំបន់ ១ ភូមិភាគពាយ័ព្យ**

៧. មន្ទីរសន្តិសុខគាស់ក្រឡ (1SS កថាខណ្ឌ ៥ និង ~~D196/1~~-ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ កថាខណ្ឌ ២(គ))

៨. អន្លង់វិលប្រែង និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធ (1SS កថាខណ្ឌ ៧)

៩. សហករណ៍ធិបតី (រួមមាន មន្ទីរសន្តិសុខវត្តធិបតី និង មន្ទីរសន្តិសុខ និងការដ្ឋានទួលម្ទេស) ( 1SS កថាខណ្ឌ ៥-៦ និង 2SS កថាខណ្ឌ ៨)។

១០. ការដ្ឋានទំនប់កង្កត (1SS កថាខណ្ឌ ៦ និង 2SS កថាខណ្ឌ ១២)

១១. មន្ទីរសន្តិសុខបាណន់ (1SS កថាខណ្ឌ ៩)

១២. មន្ទីរសន្តិសុខខ្នងគូ(Khnang Kou) ( 1SS កថាខណ្ឌ ៩ និង ~~D196/1~~-ចម្លើយតបរបស់ ស.ព.អ ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ កថាខណ្ឌ ២(ឃ))

១៣. ការដ្ឋានរោងចក្រស្ករកំពង់គុល ( 2SS កថាខណ្ឌ ៨)

១៤. ការដ្ឋានភ្នំត្រដាក់ចិត្ត (1SS កថាខណ្ឌ ៧)

១៥. ទីតាំងសម្លាប់មនុស្ស បន្ទាយអូរតាក្រី ( 3IS កថាខណ្ឌ ៦១)

១៦. ស្រុកសំឡូត ( 4SS កថាខណ្ឌ ១០-១២)

**តំបន់ ២ ភូមិភាគពាយ័ព្យ**

១៧. មន្ទីរសន្តិសុខភ្នំវាល ( 1SS កថាខណ្ឌ ១៦)

១៨. មន្ទីរសន្តិសុខស្វាយជ្រំ (1SS កថាខណ្ឌ ១៦)

01178398



១៩. ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ( 1SS កថាខណ្ឌ ១៧)

២០. ទីតាំងសម្លាប់មនុស្សព្រៃក្របៅ (1SS កថាខណ្ឌ ១៧)

២១. ទីតាំងសម្លាប់មនុស្ស វត្តចន្ទរង្សី ( 1SS កថាខណ្ឌ ១៩-២០)(យោបល់បន្ថែម៖ ស.ច.ស.អ បានឃើញកំហុសមួយនៅកថាខណ្ឌ ៤ នៃ 1SS ដែលគួរតែយោងលើកកថាខណ្ឌ ៥ ដល់ កថាខណ្ឌ ២០ មិនមែនកថាខណ្ឌ ៤ ដល់កថាខណ្ឌ ៩ ទេ។ ស.ច.ស.អ បានជូនដំណឹងថា ក.ស.ព នឹងត្រូវស្នើសុំឱ្យដាក់សំណៅកែតម្រូវ។)

**តំបន់ ៣ ភូមិភាគពាយ័ព្យ**

២២. មន្ទីរសន្តិសុខវត្តគិរីរម្យ (3IS កថាខណ្ឌ ៦0)

២៣. មន្ទីរសន្តិសុខវត្តកណ្ដាល (3IS កថាខណ្ឌ ៦៥-៦៦)

២៤. មន្ទីរសន្តិសុខវត្តបន្ទាយនាង ( 3IS កថាខណ្ឌ ៦៩)

**តំបន់ ៤ ភូមិភាគពាយ័ព្យ**

២៥. មន្ទីរសន្តិសុខវត្តធម្មយុត (3IS កថាខណ្ឌ ៦៣-៦៤)

២៦. មន្ទីរសន្តិសុខវត្តសម្ដេច (3IS កថាខណ្ឌ ៦៧)

២៧. ឃុំកំពង់ព្រៀង រួមមាន ភូមិកាច់រទេះ ភូមិថ្មី ភូមិសាលាត្រាវ និងមន្ទីរសន្តិសុខវត្តពោធិ៍លង្កា/កាច់រទេះ (3IS កថាខណ្ឌ ៦៨, 2SS កថាខណ្ឌ ៨ និង 4SS កថាខណ្ឌ ៦(គ) និង (ឃ))

២៨. ឃុំរាំងកេសី (រួមមាន វត្តរាំងកេសី និងភូមិរាំងកេសី) (2SS កថាខណ្ឌ ៤ &៨ និង 4SS កថាខណ្ឌ ៦(ក))

**តំបន់ ៥ ភូមិភាគពាយ័ព្យ**

២៩. មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង (3IS កថាខណ្ឌ ៧៤-៧៥)

៣០. ការដ្ឋានស្ពានស្រែង និងទំនប់ព្រៃរនាម (3IS កថាខណ្ឌ ៧៩)

៣១. វត្តព្រះនេត្រព្រះ ទីតាំងឃុំខ្លួន និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធនានា (3IS កថាខណ្ឌ ៧៧) និង ~~D196/1~~ ចម្លើយតបរបស់ ស.ព.អ ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ កថាខណ្ឌ ២(ខ))

៣២. មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សភូមិចក្រី (3IS កថាខណ្ឌ ៧៦)

៣៣. ទីតាំងសម្លាប់មនុស្សព្រៃតារ៉ូត (3IS កថាខណ្ឌ ៧៦ ~~D196/1~~-ចម្លើយតបរបស់ ស.ព.អ ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ កថាខណ្ឌ ២(ក))

៣៤. ទីតាំងសម្លាប់មនុស្សវត្តចម្ការខ្នុរ (3IS កថាខណ្ឌ ៧១)

៣៥. ការដ្ឋានទំបន់ត្រពាំងថ្ម (3IS កថាខណ្ឌ ៧៨)

**តំបន់ ៧ ភូមិភាគពាយ័ព្យ**

៣៦. គុកលេខ ៨ (3IS កថាខណ្ឌ ៧២)

៣៧. ទីតាំងសម្លាប់វាលបាក់ជញ្ជីង (1SS កថាខណ្ឌ ១៩)

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា គាត់ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋដូចមានខាងក្រោមក្នុងសមាសភាពរបស់គាត់ជាសមាជិក និងក្រោយមកជាលេខាស្រុកគិរីវង់ សមាជិកគណៈតំបន់ ១៣ នៅភូមិភាគនិរតី និងជាលេខាតំបន់ ១ លេខាតំបន់ ៣ លេខាតំបន់ ៤ និងជាអនុលេខាភូមិភាគពាយ័ព្យ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា គាត់ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋដូចខាងក្រោម៖

<u>**អំពើប្រល័យពូជសាសន៍**</u>

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា គាត់អាចទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនៃអំពើប្រល័យពូជសាសន៍ ដែលបានប្រព្រឹត្តមកលើខ្មែរក្រោម នៅទីតាំងដូចខាងក្រោមតាមរយៈទម្រង់នៃការទទួលខុសត្រូវដូចបានបង្ហាញខាងក្រោម៖

**តំបន់ ១៣ ភូមិភាគនិរតី**

<u>ទីតាំងឧក្រិដ្ឋកម្ម ១៖ មន្ទីរសន្តិសុខវត្តប្រធាតុ</u>

អំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ ការទទួលខុសត្រូវថ្នាក់លើ ការប្រព្រឹត្ត (*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១) និងការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ២)។

<u>ទីតាំងឧក្រិដ្ឋកម្ម ២៖ មន្ទីរសន្តិសុខក្រាំងតាចាន់</u>

អំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ*សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ៣៖ ភូមិព្រៃល</u>

អំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម និងការបង្កឡើងដោយចេតនានូវមហន្តរាយដល់ស្ថានភាពរស់នៅរបស់សង្គមមនុស្ស ដោយកម្មេសបំផ្លិចបំផ្លាញក្រុមទាំងមូល ឬផ្នែកខ្លះនៃសង្គម។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ*សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ៤៖ វត្តអង្គុណ</u>

អំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម និងការបង្កឡើងដោយចេតនានូវមហន្តរាយដល់ស្ថានភាពរស់នៅរបស់សង្គមមនុស្ស ដោយកម្មេសបំផ្លិចបំផ្លាញក្រុមទាំងមូល ឬផ្នែកខ្លះនៃសង្គម។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ*សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ៥៖ ទីតាំងសម្លាប់មនុស្សព្រៃភូមិស្លែង</u>

អំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម និងការបង្កឡើងដោយចេតនានូវមហន្តរាយដល់ស្ថានភាពរស់នៅរបស់សង្គមមនុស្ស ដោយកម្មេសបំផ្លិចបំផ្លាញក្រុមទាំងមូល ឬផ្នែកខ្លះនៃសង្គម។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ*សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ៦៖ ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមុនី</u>

អំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ*សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

**តំបន់ ១ ភូមិភាគពាយ័ព្យ**

<u>ទីតាំងឧក្រិដ្ឋកម្ម ១៣៖ រោងចក្រស្បូវកំពង់គល់</u>

អំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ*សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

**តំបន់ ២ ភូមិភាគពាយ័ព្យ**

<u>ទីតាំងឧក្រិដ្ឋកម្ម ១៧៖ មន្ទីរសន្តិសុខភូមិវាល</u>

អំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម និងការបង្កការឈឺចាប់ និងខូចខាតជាដំណំខាងផ្នែករាងកាយ ឬផ្នែកសតិបញ្ញាដល់សមាជិកទាំងឡាយនៅក្នុងក្រុម។
*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ*សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ១៨៖ មន្ទីរសន្តិសុខស្វាយជ្រំ</u>

អំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម និងការបង្កការឈឺចាប់ និងខូចខាតជាដំណំខាងផ្នែករាងកាយ ឬផ្នែកសតិបញ្ញាដល់សមាជិកទាំងឡាយនៅក្នុងក្រុម។
*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ*សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ១៩៖ ទីតាំងសម្លាប់មនុស្ស ទួលសេះញ៉ូវ</u>

អំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម។
*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ*សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ២០៖ ទីតាំងសម្លាប់មនុស្សព្រៃក្របៅ</u>

អំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម។
*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ*សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

**តំបន់ ៥ ភូមិភាគពាយ័ព្យ**

<u>ទីតាំងឧក្រិដ្ឋកម្ម ២៧៖ ឃុំកំពង់ព្រៀង រួមមាន ភូមិកាច់រទេះ ភូមិថ្មី ភូមិសាលាត្រាវ និងមន្ទីរសន្តិសុខវត្តពោធិ៍លង្កា/កាច់រទេះ</u>

អំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម។
*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ ការទទួលខុសត្រូវថ្នាក់លើ ការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ២៨៖ ឃុំរាំងកេសី</u>

អំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម។
*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ ការទទួលខុសត្រូវថ្នាក់លើ ការប្រព្រឹត្ត (*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

**<u>ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ</u>**

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា គាត់អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធដែលសំដៅលើប្រជាជនស៊ីវិល ដោយមូលហេតុសញ្ជាតិ នយោបាយ ជាតិពិន្ទុ ពូជសាសន៍ ឬសាសនា។

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា គាត់ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចខាងក្រោមនៅទីតាំងដូចខាងក្រោម៖

**តំបន់ ១៣ ភូមិភាគនិរតី**

<u>ទីតាំងឧក្រិដ្ឋកម្ម ១៖ មន្ទីរសន្តិសុខវត្តប្រធាតុ</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញមកលើ "ប្រជាជន ១៧ មេសា" ដោយមូលហេតុនយោបាយ និងមកលើខ្មែរក្រោមដោយមូលហេតុនយោបាយ និងពូជសាសន៍ តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត(ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌) និងអំពើអមនុស្សធម៌ដទៃទៀត(ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ ការទទួលខុសត្រូវថ្នាក់លើ ការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១) និងការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ២)។

<u>ទីតាំងឧក្រិដ្ឋកម្ម ២៖ មន្ទីរសន្តិសុខក្រាំងតាចាន់</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញមកលើ "ប្រជាជន ១៧ មេសា" ដោយមូលហេតុនយោបាយ និងមកលើខ្មែរក្រោមដោយមូលហេតុនយោបាយ និងពូជសាសន៍ តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត (ការផ្លាស់ទីលំនៅដោយបង្ខំ និងការឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌) និងអំពើអមនុស្សធម៌ដទៃទៀត (ការផ្លាស់ទីលំនៅដោយបង្ខំ និងការឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌)។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១) ។

<u>ទីតាំងឧក្រិដ្ឋកម្ម ៣៖ ទីតាំងសម្លាប់មនុស្សភូមិព្រៃល</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍មកលើខ្មែរក្រោម តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស និងអំពើអមនុស្សធម៌ដទៃទៀត(ការផ្លាស់ទីលំនៅដោយបង្ខំ) និងអំពើអមនុស្សធម៌ដទៃទៀត(ការផ្លាស់ទីលំនៅដោយបង្ខំ)។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ និងការប្រព្រឹត្តិ(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ៤៖ វត្តអង្គុណា</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍មកលើខ្មែរក្រោម តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ និងការប្រព្រឹត្តិ(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ៥៖ ទីតាំងសម្លាប់មនុស្សព្រៃភូមិស្លែង</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការនិរទេស ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍មកលើខ្មែរក្រោម តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការនិរទេស និងអំពើអមនុស្សធម៌ដទៃទៀត(ការផ្លាស់ទីលំនៅដោយបង្ខំ)។ និង អំពើអមនុស្សធម៌ដទៃទៀត(ការផ្លាស់ទីលំនៅដោយបង្ខំ)

*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ និងការប្រព្រឹត្តិ(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)

<u>ទីតាំងឧក្រិដ្ឋកម្ម ៦៖ ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមុនី</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍មកលើខ្មែរក្រោម តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការដាក់ក្នុងមន្ទីរឃុំឃាំង។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្តិ(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

**តំបន់ ១ ភូមិភាគពាយ័ព្យ**

<u>ទីតាំងឧក្រិដ្ឋកម្ម ៧៖ មន្ទីរសន្តិសុខគាស់ក្រឡ</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់របស់ពួកគេ តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការដាក់ក្នុងមន្ទីរឃុំឃាំង។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ ការទទួលខុសត្រូវថ្នាក់លើ និងការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ៨៖ អន្លង់វិលប្រែង និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធ</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើឱ្យទៅជាទាសករ។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ៩៖ សហករណ៍ធិបតី</u> (រួមមាន មន្ទីរសន្តិសុខវត្តធិបតី និង មន្ទីរសន្តិសុខ និងការដ្ឋានទួលម្ទេស)។

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់របស់ពួកគេ តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌) និងអំពើអមនុស្សធម៌ដទៃទៀត(ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌)។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ ការទទួលខុសត្រូវថ្នាក់លើ និងការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ១០៖ ការដ្ឋានទំនប់កង្ហត</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់របស់ពួកគេ តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌)។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ ការទទួលខុសត្រូវថ្នាក់លើ និងការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ១១៖ មន្ទីរសន្តិសុខបាណន់</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់របស់ពួកគេ តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត(ការឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌) និងអំពើអមនុស្សធម៌ដទៃទៀត(ការឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌)។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ១២៖ មន្ទីរសន្តិសុខខ្នងគូ</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់របស់ពួកគេ តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត(ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌) និងអំពើអមនុស្សធម៌ដទៃទៀត(ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌)។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ ការទទួលខុសត្រូវថ្នាក់លើ និងការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ១៣៖ រោងចក្រស្ករកំពង់គុល</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍មកលើជនជាតិវៀតណាម និងខ្មែរក្រោម តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ១៤៖ ការដ្ឋានភ្នំត្រដាក់ចិត្ត</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើឱ្យទៅជាទាសករ។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ ការទទួលខុសត្រូវថ្នាក់លើ និងការប្រព្រឹត្តិ(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ១៥៖ ទីតាំងសម្លាប់មនុស្ស បន្ទាយអូរតាគ្រី</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្តិ(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ១៦៖ ស្រុកសំឡូត</u>

*ឧក្រិដ្ឋកម្ម៖* អំពើអមនុស្សធម៌ដទៃទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ)។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្តិដោយផ្ទាល់។

**តំបន់ ២ ភូមិភាគពាយ័ព្យ**

<u>ទីតាំងឧក្រិដ្ឋកម្ម ១៧៖ មន្ទីរសន្តិសុខភ្នំវាល</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍មកលើខ្មែរក្រោម តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត(ការឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌)និងអំពើអមនុស្សធម៌ដទៃទៀត(ការឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌)។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្តិ(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ១៨៖ មន្ទីរសន្តិសុខស្វាយជ្រំ</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍មកលើខ្មែរក្រោម តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត(ការឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌) និងអំពើអមនុស្សធម៌ដទៃទៀត(ការឃុំឃាំងនៅក្នុងស្ថានភាពអមនុស្សធម៌)។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្តិ(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ១៩៖ ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍មកលើខ្មែរក្រោម តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្តិ(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ២០៖ ទីតាំងសម្លាប់មនុស្សព្រៃក្របៅ</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍មកលើខ្មែរក្រោម តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ២១៖ ទីតាំងសម្លាប់មនុស្សវត្តចន្ទ រង្សី</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ មកលើ"អ្នកជម្លៀសមកពីភូមិភាគបូព៌ា"តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

**តំបន់ ៣ ភូមិភាគពាយ័ព្យ**

<u>ទីតាំងឧក្រិដ្ឋកម្ម ២២៖ មន្ទីរសន្តិសុខវត្តគិរីរម្យ</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់របស់ពួកគេ តាមរយៈការធ្វើមនុស្សឃាត ការធ្វើឱ្យជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌) និងអំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌)។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ ការទទួលខុសត្រូវថ្នាក់លើ និងការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ២៣៖ មន្ទីរសន្តិសុខវត្តកណ្តាល</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់របស់ពួកគេ តាមរយៈបទល្មើសនៃការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត(ការឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌) និងអំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌)។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ២៤៖ មន្ទីរសន្តិសុខវត្តបន្ទាយនាង</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់របស់ពួកគេ តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌) និងអំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌)។
*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

**តំបន់ ៥ ភូមិភាគពាយ័ព្យ**

<u>ទីតាំងឧក្រិដ្ឋកម្ម ២៥៖ មន្ទីរសន្តិសុខវត្តធម្មយុត</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើ "អ្នកជម្លៀសមកពីភូមិភាគបូព៌ា"តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត(ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌) និងអំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌)។
*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ ការទទួលខុសត្រូវថ្នាក់លើ និងការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ២៦៖ មន្ទីរសន្តិសុខវត្តសម្ដេច</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់របស់ពួកគេ តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល។
*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ ការទទួលខុសត្រូវថ្នាក់លើ និងការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ២៧៖ ឃុំកំពង់ព្រៀង រួមមាន ភូមិកាច់រទេះ ភូមិថ្មី ភូមិសាលាត្រាវ និងមន្ទីរសន្តិសុខវត្តពោធិ៍លង្កា/កាច់រទេះ</u>

01178409



*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់របស់ពួកគេ តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍មកលើខ្មែរក្រោមតាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌ និងអាពាហ៍ពិពាហ៍ដោយបង្ខំ)។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ ការទទួលខុសត្រូវថ្នាក់លើ ការប្រព្រឹត្តិ(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ២៨៖ ឃុំវាំងកេសី</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍មកលើខ្មែរក្រោមតាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល និង អំពើអមនុស្សធម៌ដទៃទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ)។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ ការទទួលខុសត្រូវថ្នាក់លើ ការប្រព្រឹត្តិ (*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

**តំបន់ ៥ ភូមិភាគពាយ័ព្យ**

<u>ទីតាំងឧក្រិដ្ឋកម្ម ២៩៖ មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់របស់ពួកគេ តាមរយៈបទល្មើសនៃការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឱ្យទៅជាទាសករ និងអំពើអមនុស្សធម៌ដទៃទៀត(ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌) និង អំពើអមនុស្សធម៌ដទៃទៀត(ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌)។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្តិ (*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ៣០៖ ការដ្ឋានស្ពានស្រែង និងទំនប់ព្រៃរនាម</u>

01178410



*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌)។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត (*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ៣១៖ វត្តព្រះនេត្រព្រះ ទីតាំងឃុំខ្លួន និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធនានា</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់របស់ពួកគេ តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការដាក់ក្នុងមន្ទីរឃុំឃាំង។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត (*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ៣២៖ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សភូមិចក្រី</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត (*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ៣៣៖ ទីតាំងសម្លាប់មនុស្សព្រៃតារ៉ត</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត (*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ៣៤៖ ទីតាំងសម្លាប់មនុស្សវត្តចម្ការខ្នុរ</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត (*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ៣៥៖ ការដ្ឋានត្រពាំងថ្ម</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់របស់ពួកគេ តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌) និងអំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌)។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត (*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

01178411



**តំបន់ ៧ ភូមិភាគពាយ័ព្យ**

ទីតាំងឧក្រិដ្ឋកម្ម ៣៦៖ គុកលេខ ៨

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើ"អ្នកជម្លៀសមកពីភូមិភាគបូព៌ា"តាមរយៈបទល្មើសនៃការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំង/ធ្វើការក្នុងស្ថានភាពអមនុស្សធម៌) និងអំពើអមនុស្សធម៌ដទៃទៀត (ការឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌)

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត (*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)

ទីតាំងឧក្រិដ្ឋកម្ម ៣៧៖ ទីតាំងសម្លាប់មនុស្ស វាលបាក់ជញ្ជីង

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើ"អ្នកជម្លៀសមកពីភូមិភាគបូព៌ា"តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត (*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

**អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩**

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា គាត់អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរដូចមានខាងក្រោម តាមរយៈទម្រង់នៃការទទួលខុសត្រូវដូចមានខាងក្រោមដែលបានប្រព្រឹត្តជាផ្នែកមួយនៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាងកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម។

**តំបន់ ១៣ ភូមិភាគនិរតី**

ទីតាំងឧក្រិដ្ឋកម្ម ២៖ មន្ទីរសន្តិសុខក្រាំងតាចាន់

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាតដោយចេតនា ការផ្លាស់ទីលំនៅជនស៊ីវិលដោយខុសច្បាប់។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការប្រព្រឹត្ត(*តាមរយៈ*សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

ទីតាំងឧក្រិដ្ឋកម្ម ៣៖ ទីតាំងសម្លាប់មនុស្ស ភូមិព្រៃល

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាតដោយចេតនា ការនិរទេស ឬការផ្លាស់ទីលំនៅជនស៊ីវិលដោយខុសច្បាប់។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ និងការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ៤៖ វត្តអង្គុណ</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាតដោយចេតនា។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ និងការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

<u>ទីតាំងឧក្រិដ្ឋកម្ម ៥៖ ទីតាំងសម្លាប់មនុស្ស ភូមិស្លែង</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាតដោយចេតនា ការនិរទេស ឬការផ្លាស់ទីលំនៅជនស៊ីវិលដោយខុសច្បាប់។

*ទម្រង់នៃការទទួលខុសត្រូវ៖* ការរៀបចំផែនការ ការបញ្ជា ការញុះញង់ និងការប្រព្រឹត្ត(*តាមរយៈ* សហឧក្រិដ្ឋកម្មរួមប្រភេទទី ១)។

**<u>ការរំលោភលើមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦</u>**

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា គាត់អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការរំលោភលើមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។ ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា ការរំលោភលើមាត្រា ៥០១ និង ៥០៦ (មនុស្សឃាតដោយចេតនា)នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ មានចែង និងផ្តន្ទាទោសតាមមាត្រា ៣ (ថ្មី) និង ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា គាត់ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទមនុស្សឃាតដោយចេតនា ដែលបានប្រព្រឹត្តនៅទីតាំងដូចខាងក្រោមតាមរយៈទម្រង់នៃការទទួលខុសត្រូវដូចខាងក្រោម៖

**តំបន់ ១៣ ភូមិភាគនិរតី**

ទីតាំងឧក្រិដ្ឋកម្ម ១៖ មន្ទីរសន្តិសុខវត្តប្រធាតុ តាមរយៈការរៀបចំផែនការ ការបញ្ជា និងការប្រព្រឹត្ត (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ២៖ មន្ទីរសន្តិសុខក្រាំងតាចាន់ តាមរយៈការប្រព្រឹត្តិ (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ៣៖ ទីតាំងសម្លាប់មនុស្សភូមិព្រេល តាមរយៈការរៀបចំផែនការ ការបញ្ជា និង ការប្រព្រឹត្តិ (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម៤៖ វត្តអង្គុណា តាមរយៈការរៀបចំផែនការ ការបញ្ជានិងការប្រព្រឹត្តិ(សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ៥៖ ទីតាំងសម្លាប់មនុស្សព្រៃភូមិស្វែង តាមរយៈការរៀបចំផែនការ ការបញ្ជា និងការប្រព្រឹត្តិ (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ៦៖ ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមុនី តាមរយៈការប្រព្រឹត្តិ(សហចារី)។

**តំបន់ ១ ភូមិភាគពាយ័ព្យ**

ទីតាំងឧក្រិដ្ឋកម្ម ៧៖ មន្ទីរសន្តិសុខគាស់ក្រឡ តាមរយៈការរៀបចំផែនការ ការបញ្ជា និងការប្រព្រឹត្តិ (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ៨៖ អន្លង់វិលប្រែង និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធ តាមរយៈការប្រព្រឹត្តិ(សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ៩៖ សហករណ៍ធិបតី (រួមមាន មន្ទីរសន្តិសុខវត្តធិបតី និង មន្ទីរសន្តិសុខ និងការដ្ឋានទួលម្ទេស) តាមរយៈការរៀបចំផែនការ ការបញ្ជា និងការប្រព្រឹត្តិ (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ១០៖ ការដ្ឋានទំនប់ កង្ហត តាមរយៈការរៀបចំផែនការ ការបញ្ជា និងការប្រព្រឹត្តិ (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ១១៖ មន្ទីរសន្តិសុខបាណន់ តាមរយៈការប្រព្រឹត្តិ (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ១២៖ មន្ទីរសន្តិសុខខ្នងគូ តាមរយៈការរៀបចំផែនការ ការបញ្ជា និងការប្រព្រឹត្តិ (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ១៣៖ការដ្ឋានរោងចក្រស្ករកំពង់គុល តាមរយៈការប្រព្រឹត្តិ (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ១៥៖ ទីតាំងសម្លាប់មនុស្សបន្ទាយអូរតាក្រី តាមរយៈការប្រព្រឹត្តិ (សហចារី)។

**តំបន់ ២ ភូមិភាគពាយ័ព្យ**

ទីតាំងឧក្រិដ្ឋកម្ម ១៧៖ មន្ទីរសន្តិសុខភ្នំវាល តាមរយៈការប្រព្រឹត្តិ (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ១៨៖ មន្ទីរសន្តិសុខស្វាយជ្រំ តាមរយៈការប្រព្រឹត្តិ (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ១៩៖ ទួលសេះញ៉ៅ តាមរយៈការប្រព្រឹត្តិ (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ២០៖ ទីតាំងសម្លាប់មនុស្សព្រៃក្របៅ តាមរយៈការប្រព្រឹត្តិ (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ២១៖ ទីតាំងសម្លាប់មនុស្សវត្តចន្ទរង្សី តាមរយៈការប្រព្រឹត្ត (សហចារី)។

**តំបន់ ៣ ភូមិភាគពាយ័ព្យ**

ទីតាំងឧក្រិដ្ឋកម្ម ២២៖ មន្ទីរសន្តិសុខវត្តគិរីរម្យ តាមរយៈការរៀបចំផែនការ ការបញ្ជា និងការប្រព្រឹត្ត (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ២៣៖ មន្ទីរសន្តិសុខវត្តកណ្តាល តាមរយៈការប្រព្រឹត្ត (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ២៤៖ មន្ទីរសន្តិសុខវត្តបន្ទាយនាង តាមរយៈការប្រព្រឹត្ត (សហចារី)។

**តំបន់ ៤ ភូមិភាគពាយ័ព្យ**

ទីតាំងឧក្រិដ្ឋកម្ម ២៥៖ មន្ទីរសន្តិសុខវត្តធម្មយុត តាមរយៈការរៀបចំផែនការ ការបញ្ជា និងការប្រព្រឹត្ត (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ២៦៖ មន្ទីរសន្តិសុខវត្តសម្តេច តាមរយៈការរៀបចំផែនការ ការបញ្ជា និងការប្រព្រឹត្ត (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ២៧៖ ឃុំកំពង់ព្រៀង រួមមាន ភូមិកាច់រទេះ ភូមិថ្មី ភូមិសាលាត្រាវ មន្ទីរសន្តិសុខវត្តពោធិ៍លង្កា/កាច់រទេះ តាមរយៈការរៀបចំផែនការ ការបញ្ជា និងការប្រព្រឹត្ត (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ២៨៖ ឃុំរាំងកេសី តាមរយៈការប្រព្រឹត្ត (សហចារី)។

**តំបន់ ៥ ភូមិភាគពាយ័ព្យ**

ទីតាំងឧក្រិដ្ឋកម្ម ២៩៖ មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង តាមរយៈការប្រព្រឹត្ត (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម៣០៖ ការដ្ឋានស្ពានស្រែង និងទំនប់ព្រៃនាម តាមរយៈការប្រព្រឹត្ត (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ៣១៖ វត្តព្រះនេត្រព្រះ ទីតាំងឃុំខ្លួន និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធនានា តាមរយៈការប្រព្រឹត្ត (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ៣២៖ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សភូមិចក្រី តាមរយៈការប្រព្រឹត្ត (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ៣៣៖ ទីតាំងសម្លាប់មនុស្សព្រៃតារ៉ូត តាមរយៈការប្រព្រឹត្ត (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ៣៤៖ ទីតាំងសម្លាប់មនុស្សវត្តចម្ការខ្នុរ តាមរយៈការប្រព្រឹត្ត (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ៣៥៖ ការដ្ឋានទំបន់ត្រពាំងថ្ម តាមរយៈការប្រព្រឹត្ត (សហចារី)។

**តំបន់ ៧ ភូមិភាគពាយ័ព្យ**

ទីតាំងឧក្រិដ្ឋកម្ម ៣៦៖ គុកលេខ ៨ តាមរយៈការប្រព្រឹត្ត (សហចារី)។

ទីតាំងឧក្រិដ្ឋកម្ម ៣៧៖ ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជ្រីង តាមរយៈការប្រព្រឹត្តិ (សហចារី)។

~~ការធ្វើកំណត់ហេតុនេះឈប់សម្រាក នៅម៉ោង 13:38 រហូតដល់ម៉ោង 13:58 នាទី~~

**<u>សហឧក្រិដ្ឋកម្មរួម</u>**

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា គាត់អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចបានបង្ហាញខាងលើ និងបានកើតឡើងនៅក្នុងតំបន់ ១,២, ៣, ៤, ៥ និង ៧ នៅភូមិភាគពាយ័ព្យ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ *ជាអាទិ៍* តាមរយៈការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម។ ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា គិតចាប់តាំងពីដើមឆ្នាំ ១៩៧៧ ឬពាក់កណ្តាលឆ្នាំ ១៩៧៧ យ៉ាងហោចណាស់រហូតដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ តា ម៉ុក ដោយសហការជាមួយនឹង យឹម ទិត្យ, អ៊ឹម ចែម, តា ចាយ និងកម្មាភិបាលភូមិភាគនិរតីផ្សេងទៀតដែលគេទុកចិត្ត និងឲ្យតំណែងនៅថ្នាក់ភូមិភាគ តំបន់ និងស្រុកនៅភូមិភាគពាយ័ព្យ បានរៀបចំ សម្របសម្រួល និងអនុវត្តប្រតិបត្តិការមួយដើម្បីអនុវត្តឲ្យបានជោគជ័យនូវគោលនយោបាយដូចខាងក្រោមរបស់បក្សកុម្មុយនីស្តកម្ពុជា("ប.ក.ក")នៅភូមិភាគពាយ័ព្យ៖

- ការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋាន ដែលបានអនុវត្តតាមរយៈការធ្វើឲ្យប្រជាជនក្លាយជាទាសករ។
- ការដាក់បទបញ្ជាលើអាពាហ៍ពិពាហ៍ ដែលបានអនុវត្ត*ជាអាទិ៍* តាមរយៈការរៀបចំអាពាហ៍ពិពាហ៍ឲ្យអ្នកនៅភូមិភាគពាយ័ព្យដោយបង្ខំ។
- ការកសាង"សមាសភាពមិនល្អ"តាមរយៈការដាក់ក្នុងមន្ទីរឃុំឃាំង ពលកម្មដោយបង្ខំ និងការដាក់"សមាសភាពមិនល្អ"ឲ្យស្ថិតនៅក្នុងស្ថានភាពអមនុស្សធម៌ និងការសម្លាប់"ខ្មាំង" និង"សមាសភាពមិនល្អ"ទាំងនៅក្នុងជួរ ប.ក.ក ទាំងនៅក្រៅជួរ ប.ក.ក និង
- ការដាក់មុខសញ្ញាលើក្រុមជាក់លាក់នានា គឺ កម្មាភិបាល ប.ក.ក នៅភូមិភាគពាយ័ព្យ អតីតមន្ត្រីសាធារណរដ្ឋខ្មែរ រួមមានទាំងមន្ត្រីស៊ីវិល ទាំងអតីតទាហាន និងគ្រួសាររបស់ពួកគេ។

អ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមនេះ មានចេតនា និងបានអនុវត្តគោលនយោបាយទាំងនេះតាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក គឺ ឧក្រិដ្ឋកម្មប្រឆាំង

មនុស្សជាតិ ក្នុងនោះរួមមាន ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ អំពើអមនុស្សធម៌ដទៃទៀត និងការធ្វើទុក្ខបុកម្នេញ។

ទាក់ទងនឹងខ្មែរក្រោម ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា គាត់អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅភូមិភាគនិរតី នៅមន្ទីរសន្តិសុខវត្តប្រធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីតាំងសម្លាប់មនុស្សភូមិព្រេល ទីតាំងសម្លាប់មនុស្សវត្តអង្គុណា ទីតាំងសម្លាប់មនុស្សព្រៃភូមិស្វែង ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមុនី ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅភូមិភាគពាយ័ព្យ នៅការដ្ឋានរោងចក្រស្ករកំពង់គុល មន្ទីរសន្តិសុខភ្នំវាល មន្ទីរសន្តិសុខស្វាយជ្រៃ ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ ទីតាំងសម្លាប់មនុស្សព្រៃក្របៅ ឃុំកំពង់ព្រៀង (រួមមាន ភូមិកាច់រទេះ ភូមិថ្មី ភូមិសាលាត្រាវ មន្ទីរសន្តិសុខវត្តពោធិ៍លង្កា/កាច់រទេះ) និងឃុំរាំងកេសី តាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម។ សហឧក្រិដ្ឋកម្មរួមនេះ បានកើតឡើងយ៉ាងហោចណាស់ចាប់តាំងពីឆ្នាំ ១៩៧៦ រហូតដល់ខែ មករា ឆ្នាំ ១៩៧៩ ហើយរួមមាន តា ម៉ុក, យឹម ទិត្យ, ខៀវ តុំ, យាយ បូ, ពេជ្រ ជឹម, សេក សំអាត ហៅ យាយ រឹម និងកម្មាភិបាលភូមិភាគនិរតី ដែលបានចូលរួមគោលដៅរួមក្នុងការអនុវត្តផែនការទូទាំងប្រទេសដើម្បីលុបបំបាត់ទាំងស្រុង ឬផ្នែកខ្លះនៃក្រុមខ្មែរក្រោមនៅក្នុងតំបន់ជាក់លាក់នានាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

អ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមនេះ មានចេតនា និងបានអនុវត្តផែនការនេះតាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក គឺអំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម ការបង្កការឈឺចាប់ និងខូចខាតជាដំណំខាងផ្នែករាងកាយ ឬផ្នែកសតិបញ្ញាដល់សមាជិកទាំងឡាយនៅក្នុងក្រុម និងការបង្កឡើងដោយចេតនានូវមហន្តរាយដល់ស្ថានភាពរស់នៅរបស់សង្គមមនុស្ស ដោយកម្មេសបំផ្លិចបំផ្លាញក្រុមទាំងមូល ឬផ្នែកខ្លះនៃសង្គម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងនោះរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃទៀត និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។

ចុងក្រោយ ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា គាត់អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខវត្តប្រធាតុ តាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម។ សហឧក្រិដ្ឋកម្មរួមនេះ បានកើតឡើងយ៉ាងហោចណាស់ចាប់តាំងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ហើយរួមមាន យឹម ទិត្យ, ខៀវ តុំ, យាយ បូ, តា

ព្រឹង និងបុគ្គលិកមន្ទីរសន្តិសុខ ដែលបានចូលរួមគោលដៅរួមក្នុងការជំរុញឲ្យមានការធ្វើបាបជាប្រព័ន្ធ។

អ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមនេះ មានចេតនា និងបានអនុវត្តផែនការនេះតាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក គឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងនោះរួមមាន ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឲ្យទៅជាទាសករ ការធ្វើទារុណកម្ម ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល អំពើអមនុស្សធម៌ដទៃទៀត ការធ្វើទុក្ខបុកម្នេញ និងអំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់ និងការបង្កការឈឺចាប់ និងខូចខាតជាដំណំខាងផ្នែករាងកាយ ឬផ្នែកសតិបញ្ញាដល់ក្រុម។

## ការបង្ហាញអំពីទីតាំងឧក្រិដ្ឋកម្មដែលមិនត្រូវស៊ើបអង្កេតបន្ថែមទៀត

ស.ច.ស.អ បានប្រកាសថា បច្ចុប្បន្ននេះ គាត់កំពុងពិចារណាមិនស៊ើបអង្កេតថែមទៀតលើការចោទប្រកាន់ដូចខាងក្រោម ហើយនឹងអញ្ជើញភាគីទាំងអស់ក្នុងថិរវេលាសមស្រប ដើម្បីធ្វើបទបង្ហាញអំពីបញ្ហានេះ៖

- ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងមន្ទីរសន្តិសុខវត្តសុបិន (1SS កថាខណ្ឌ ១២)
- ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងភូមិសោម (1SS កថាខណ្ឌ ១២)
- ការចោទប្រកាន់ទាក់ទងនឹងការដាក់មុខសញ្ញាលើក្រុមខ្មែរក្រោម និងវៀតណាមនៅសហករណ៍ធិបតី (2SS កថាខណ្ឌ ~~១២~~) ១៤
- ការចោទប្រកាន់ទាក់ទងនឹងមន្ទីរសន្តិសុខវត្តបន្ទាយត្រែង (3IS កថាខណ្ឌ ៦២)
- ការចោទប្រកាន់អំពីការសម្លាប់រួមនៅភ្នំត្រដាក់ចិត្ត (1SS កថាខណ្ឌ ៧)
- ការចោទប្រកាន់ទាក់ទងនឹងទីតាំងសម្លាប់មនុស្សដំណាក់វាំង (1SS កថាខណ្ឌ ៩)
- ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងគុកត្រាចក្រោល ហៅ គុកបឹងបាតកណ្តាល (1SS កថាខណ្ឌ ១៦ និង 2SS កថាខណ្ឌ ៧)
- ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ (3IS កថាខណ្ឌ ៧៣)
- ការចោទប្រកាន់អំពីអំពើហិង្សាផ្លូវភេទមកលើខ្មែរក្រោម និង "អ្នកជម្លៀសមកពីភូមិភាគបូព៌ា"នៅស្រុកបាកាន តំបន់ ២ ភូមិភាគពាយ័ព្យ (2SS កថាខណ្ឌ ៧)
- ការចោទប្រកាន់ទាក់ទងនឹងល្អាងគួយយំ (3IS កថាខណ្ឌ ៧០)

01178418



- ការចោទប្រកាន់ទាក់ទងនឹងការដាក់មុខសញ្ញាលើជនជាតិវៀតណាមនៅក្នុងឃុំរាំងកេសី (2SS កថាខណ្ឌ ៨)
- ការចោទប្រកាន់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំនៅភូមិក្រហុក ឃុំបាណន់ (2SS កថាខណ្ឌ ៦ និង 4SS កថាខណ្ឌ ៦)
- ការចោទប្រកាន់ទាក់ទងនឹងការដាក់មុខសញ្ញាលើជនជាតិវៀតណាមនៅស្រុកព្រះនេត្រព្រះ (2SS កថាខណ្ឌ ៩)។

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា មុនពេលបញ្ចប់កិច្ចស៊ើបសួរ ស.ច.ស.អ អាចសម្រេចដាក់គាត់ឲ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋបន្ថែមទៀតដោយផ្អែកតាមការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋាន និងចម្លើយតប ប្រសិនបើ ស.ច.ស.អ ជឿជាក់ថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា យឹម ទិត្យ អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋបែបនោះ។ ពេលនោះ យឹម ទិត្យ នឹងត្រូវបានកោះហៅឲ្យមកបង្ហាញខ្លួនម្តងទៀត និងទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី។

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា៖

- នៅគ្រប់ពេលទាំងអស់នៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតរបស់តុលាការ គាត់មានសិទ្ធិស្នើឲ្យ ស.ច.ស.អ ចេញដីកា ឬចាត់វិធានការស៊ើបអង្កេតដែលគាត់យល់ថា មានប្រយោជន៍សម្រាប់ការស៊ើបអង្កេត ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៥៥(១០) និង ៥៨(៦)។
- គាត់នឹងទទួលបានពេលវេលាសមហេតុផលដើម្បីពិនិត្យមើលសំណុំរឿង និងចូលរួមកិច្ចស៊ើបសួរ។
- មេធាវីរបស់គាត់ មានសិទ្ធិពិគ្រោះជាមួយនឹងសំណុំរឿងដើម អាស្រ័យតាមដែនកំណត់សមហេតុផល ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីបន្តដំណើរការទៅមុខ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៥៥(១១)។

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា នៅពេលនេះ គាត់នឹងមិនជាប់ឃុំខ្លួនបណ្តោះអាសន្នទេ ប៉ុន្តែ គាត់ត្រូវតែបង្ហាញខ្លួនតាមតម្រូវការរបស់ អ.វ.ត.ក។

01178419

០០៥/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស លេខ៖ ១២៥១

[redacted]

[redacted]

[redacted]

មូលដ្ឋានរបស់គាត់នៅ

យឹម ទិត្យ ~~បាន~~ ស្ម័គ្រចិត្តប្រគល់លិខិតឆ្លងដែនរបស់គាត់ ជូនទៅប៉ុស្តិ៍នគរបាលនៅខេត្តបាត់ដំបង ហើយចង្អុលបង្ហាញថា គាត់អាចត្រូវការលិខិតឆ្លងដែននេះសម្រាប់ការធ្វើដំណើរយូរៗម្តងដើម្បីទៅពិនិត្យសុខភាពនៅប្រទេសថៃ ហើយបានយល់ព្រមនៅផ្ទះនៅពេលដែលនគរបាលមូលដ្ឋានចុះពិនិត្យប្រចាំសប្តាហ៍ទៅតាមកាលបរិច្ឆេទ និងពេលវេលាដែលនឹងត្រូវរៀបចំតាមក្រោយ។

ស.ច.ស.អ បានប្រកាសថា ចំពោះបញ្ហានេះ គាត់នឹងចេញដីកាបង្គាប់ទៅនគរបាលយុត្តិធម៌របស់ អ.វ.ត.ក ក្នុងថិរវេលាសមស្រប។

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា គាត់ត្រូវតែជូនដំណឹង ស.ច.ស.អ ប្រសិនបើមានការផ្លាស់ប្តូរអាសយដ្ឋាន។

២៧

ស.ច.ស.អ បានជូនដំណឹង យឹម ទិត្យ ថា តាមវិធាន ៥៧(៣)(ខ)នៃវិធានផ្ទៃក្នុង រាល់ការប្រគល់ឯកសារនានា ឬការជូនដំណឹងទាំងអស់ទៅតាមអាសយដ្ឋានចុងក្រោយ នឹងត្រូវចាត់ទុកថាមានសុពលភាព។

យឹម ទិត្យ បានយល់ព្រមឱ្យប្រគល់ឯកសារនានាទៅគាត់តាមរយៈអ៊ីមែលផ្ញើទៅសហមេធាវីណាម្នាក់ ឬច្រើននាក់ក្នុងចំណោមសហមេធាវីរបស់គាត់។

យឹម ទិត្យ បានលះបង់សិទ្ធិដោយមិនឱ្យអានកំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងនេះ ជាភាសាខ្មែរទេ។

ការថតយកសំឡេង/រូបភាពបានបញ្ចប់នៅ [illegible] ២២ [illegible]។

សំណៅដើមនៃខ្សែអាត់ជាសំឡេង/រូបភាពនៃការបង្ហាញខ្លួនលើកដំបូងនេះ ត្រូវបានបិទស្លាក និងប្រថាប់ត្រានៅចំពោះមុខ យឹម ទិត្យ និងសហមេធាវីរបស់គាត់។ យឹម ទិត្យ សហមេធាវីរបស់គាត់ ក្រឡាបញ្ជី និង ស.ច.ស.អ បានចុះហត្ថលេខាលើសំណៅដើមនៃខ្សែអាត់ជាសំឡេង/រូបភាពដែលបានប្រថាប់ត្រានេះ។ សំណៅមួយច្បាប់នៃខ្សែអាត់ជាសំឡេង/រូបភាពនេះបានប្រគល់ជូន យឹម ទិត្យ។

សំណៅមួយច្បាប់នៃកំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងនេះបានប្រគល់ជូន យឹម ទិត្យ។

យឹម ទិត្យ មិនមានការជំទាស់ ហើយបានយល់ព្រមផ្តិតមេដៃលើកំណត់ហេតុនេះ។

ការបង្ហាញខ្លួនលើកដំបូងនេះបានបញ្ចប់នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥ វេលាម៉ោង ១៤:៥៥ នាទី។

| | | |
|---|---|---|
| **ចៅក្រម Michael Bohlander** | **យឹម ទិត្យ** | **ឆាយ ច័ន្ទលីដា** |
| **សហចៅក្រមស៊ើបអង្កេតអន្តរជាតិ** | **ជនត្រូវចោទ** | **ក្រឡាបញ្ជី** |
| *ហត្ថលេខា* | *ហត្ថលេខា/ស្នាមមេដៃ* | *ហត្ថលេខា* |
| | | ២៨ |

**សូ មុំស្មៀន្នី**
**សហមេធាវីជាតិរបស់ យឹម ទិត្យ**

*ហត្ថលេខា*

**Suzana Tomanović**
**សហមេធាវីអន្តរជាតិរបស់**
**យឹម ទិត្យ**

*ហត្ថលេខា*

**សូរ សុខាល័យ**
**អ្នកបកប្រែភាសា**

*ហត្ថលេខា*

**ទូន គីមលី**
**អ្នកបកប្រែភាសា**

*ហត្ថលេខា*